**ចំណុចសំខាន់ៗ**

## ស្ថានភាពទូទៅនៃការធ្វើវិនិយោគផ្នែកជីវបរិស្ថាន/ការគ្រប់គ្រងដំណាំដាំដុះ៖ ២០១២

**ដោយ Clive James, អ្នកផ្តួចផ្តើម និងជាប្រធាន ISAAA**

*អ្នករៀបរៀងសូមឧទ្ទិសចំពោះអ្នកក្រីក្រ និងអ្នកទទួលរងការស្រេកឃ្លាន ព្រមទាំងបានរស់រានមានជីវិតចំនួន១កោដនាក់*

---

*ការដាំដុះបែបជីវបរិស្ថានមានការកើនឡើងយ៉ាងខ្លាំងដោយមិននឹកស្មានដល់ពី១.៧លានហិចតានៅឆ្នាំ១៩៩៦ រហូតដល់១៧០លានហិចតានៅឆ្នាំ២០១២*

យោងតាមការស្រង់ស្ថិតិបានអោយដឹងថា ការដាំដុះបែបជីវបរិស្ថានមានការកើនឡើងជាសាកលចំនួន ១៧០,៣លានហិចតានៅឆ្នាំ២០១២នេះ ជាមួយនឹងអាត្រាកំនើនប្រចាំឆ្នាំចំនួន៦% ដែលកំណើននេះមានការកើនឡើងពី១០.៣ដល់១៦០លានហិចតានៅឆ្នាំ២០១១។

តាមការកត់សម្គាល់នៅក្នុងឆ្នាំ២០១២ ឃើញថាការដាំដុះបែបជីវបរិស្ថានមានការកើនឡើងយ៉ាងខ្លាំងដោយមិន និកស្មានដល់ ពី១.៧លានហិចតានៅឆ្នាំ១៩៩៦រហូតដល់១៧០លានហិចតានៅឆ្នាំ២០១២ ការកើនឡើងនេះដោយសាការទទួលយកយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាក្នុងការដាំដុះនាពេលថ្មីៗនេះ និងជាហេតុផលដែលពួក គេបានទទួលផលផងដែរ។

នៅកំឡុងពេលពីឆ្នាំ១៩៩៦ដល់២០១២ កសិកររាប់លាននាក់នៅបណ្តាលប្រទេសចំនួន៣០លើពិភពលោក បានធ្វើការសម្រេចចិត្តដោយឯករាជ្យបំផុតក្នុងការដាំដុះបន្ថែមនៅលើផ្ទៃដី១.៥លានហិចតា ការដាំដុះនេះមានចំនួនលើស៥០%នៃផ្ទៃដីសរុបរបស់សហរដ្ឋអាមេរិកឬប្រទេសចិន ដែលនេះ បានបង្ហាញនូវទំនុកចិត្ត និងការជឿ ជាក់ ដែលកន្លងមកកសិករធ្លាប់ព្រួយបារម្ភចំពោះហានិភ័យរាប់លាននៃការដាំដុះបែបជីវបរិស្ថានដែលផ្តល់និរន្តភាព និងអត្ថប្រយោជន៍ជាច្រើនលើសលប់ផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថាននេះ។

មានប្រទេសថ្មីចំនួនពីរ គឺប្រទេសស៊ុលដង់(កម្បាស) និងប្រទេសគុយបា(ពោត) ដែលបានដាំដំណាំទាំងនេះ ជាលើកទីមួយនៅក្នុងឆ្នាំ២០១២។ ប្រទេសអាឡឺម៉ង់ និងស៊ុយអ៊ែតមិនអាចដាំដំឡូង”Amflora” ដោយសារលែង មានតម្រូវការទីផ្សារ ហើយប្រទេសប៉ូឡូញក៏ឈប់ដាំពោតទៀតដោយសារការលំបាកផ្នែកផ្លូវច្បាប់។

នៅក្នុងចំណោមប្រទេសចំនួន២៨ដែលបានដាំដំណាំជីវបរិស្ថាននៅឆ្នាំ២០១២ មានប្រទេសចំនួន២០ជា ប្រទេសកំពុងធ្វើការអភិវឌ្ឍន៍ និង៨ប្រទេសជាប្រទេសឧស្សាហ៍កម្ម នេះដោយធ្វើការប្រៀបធៀបជាមួយប្រទេសកំពុងធ្វើការអភិវឌ្ឍន៍ចំនួន១៩ និងប្រទេសឧស្សាហ៍កម្មចំនួន១០កាលពីឆ្នាំ២០១១។

នៅក្នុងឆ្នាំ២០១២ ស្ថិតិបានបង្ហាញអោយឃើញថាមានកសិករចំនួន១៧.៣លាននាក់ ដែលចំនួននេះមានការ កើនឡើង០.៦លាននាក់ជាងកាលពីឆ្នាំ២០១១ដែលបានដាំដំណាំជីវបរិស្ថាន និងត្រូវបានកត់សម្គាល់ឃើញថាលើស៩០% ឬជាង១៥លាននាក់ដែលជាគ្រួសារក្រីក្រតូចតាចនៅក្នុងប្រទេសកំពុងធ្វើការអភិវឌ្ឍន៍។ ដោយសារ កសិករចង់រួចផុតពីហានិភ័យ នៅក្នុងឆ្នាំ២០១២ មានគ្រួសារកសិករចំនួន៧.២នៅប្រទេសចិន និង៧.២ទៀតនៅប្រទេសឥណ្ឌាបានសម្រេចចិត្តដាំកម្បាសនៅលើផ្ទៃដីជិត១៥ហិចតា ដោយសារដំណាំនេះផ្តល់អត្ថ ប្រយោជន៍ច្រើនបែបច្រើនយ៉ាង។

កាលពីដើមឡើយ បណ្តាលប្រទេសកំពុងអភិវឌ្ឍបានដាំដំណាំនេះដល់ទៅ៥២%ច្រើនជាងប្រទេសឧស្សាហ៍កម្ម ដែលមានចំនួនតែ៤៨%នៅឆ្នាំ២០១២។ នៅក្នុងឆ្នាំ២០១២ កំណើននៃការដាំដំណាំជីវបរិស្ថានមានការកើនឡើងយ៉ាងហោចចំនួន៣ដង និងចំនួន៥ដងធំជាងប្រទេសកំពុងអភិវឌ្ឍ ដែលទូរលេខនោះស្មើនឹង១១% ឬ៨.៧ លានហិចតាធៀបទៅនឹង៣% ឬ១.៦លានហិចតានៅបណ្តាលប្រទេសឧស្សាហ៍កម្ម។

កក្តាហានិភ័យគឺជាចំណុចដ៏សំខាន់មួយ ក្នុងចំណោមប្រទេសទាំង១៣ដែលមានដាំដំណាំជីវបរិស្ថានពីរ ឬច្រើន ប្រភេទនៅក្នុងឆ្នាំ២០១២ គឺមាន១០ប្រទេសជាប្រទេសកំពុងធ្វើការអភិវឌ្ឍន៍ត្រូវបានលើកទឹកចិត្ត ផ្ទៃដីចំនួន៤៣.៧លានហិចតា ឬច្រើនជាងមួយភាគបួនក្នុងចំណោម១៧០លានហិចតាត្រូវបានជំរុញអោយធ្វើការដាំដុះ កាលពីឆ្នាំ២០១២។

នៅក្នុងរយៈពេល៤ឆ្នាំនេះ ប្រទេសប្រេស៊ីលមានការរីកចំរើនជាសាកលដោយកំណើននៃផ្ទៃដីដាំដំណាំជីវបរិស្ថាន មានការកើនឡើងជាងប្រទេសដទៃទៀត វាជាមោទនភាពដែលកំណើននេះបានកើនឡើងពី៦.៣លានហិចតា ស្មើនឹង២១%នៅឆ្នាំ២០១១ រហូតដល់៣៦.៦លានហិចតា។

សហរដ្ឋអាមេរិកនៅបន្តជាប្រទេសឈានមុខក្នុងការដាំដុះជាមួយនឹងផ្ទៃដី៦៩.៥ហិចតា ដែលជាមធ្យម៩០% បានទទួលយកការដាំដុះដំណាំគ្រប់ប្រភេទ។ ដោយសារឥទ្ធិពលនៃគ្រោះរាំងស្ងួតកាលពីឆ្នាំ២០១២ សហរដ្ឋអាមេរិកបានបាត់បង់ផលិតផលពោត២១% និងសណ្តែកសៀងចំនួនចំនួន១២%។ ចំណែកនៅប្រទេស កាណាដាត្រូវបានគេកត់សម្គាល់ថាផ្ទៃដីចំនួន៨.៤លានហិចតា ដែលស្មើនឹង៩៧.៥%ត្រូវបានគេទទួលយកធ្វើការដាំដុះ។

រីឯនៅប្រទេសឥណ្ឌាបានធ្វើការដាំដុះកប្បាស១០.៨លានហិចតាជាមួយអាត្រាទទួលយក៩៣% ខណៈដែល គ្រួសារកសិករតូចដែលមានធនធានតិចតួចចំនួន៧.២លានគ្រួសារនៅប្រទេសចិន បានដាំកប្បាសចំនួន៤.០លានហិចតាជាមួយនឹងអត្រាទទួលយក៨០% និងប្រមូលផល០.៥ហិចតាក្នុងមួយគ្រួសារ។ នៅប្រទេសឥណ្ឌា គេអាចរកប្រាក់ចំណូលពីដំណាំកប្បាសចំនួន១២.៦លានដុល្លារអាមេរិកពីឆ្នាំ២០០២ដល់២០១១ និង៣.២លានដុល្លារនៅឆ្នាំ២០១១។

អាហ្វ្រិចបានបន្តរការរីកចំរើននៅអាហ្វ្រិចខាងត្បូងដោយកើនឡើងតំបន់ជីវបរិស្ថានពី០.៦ ដល់២.៩លានហិចតា ដោយប្រទេសស៊ូដង់បានរួមជាមួយប៊ូគីណាហ្វាសូ និងប្រទេសអេស្ស៊ីបក្នុងការជំរុញការកើនឡើងនូវដំណាំជីវបរិស្ថានដល់កំរិតលេខ៤។

ប្រទេសចំនួន៥ទៀតនៅអឺរ៉ុបបានដាំពោតជីវបរិស្ថានចំនួន១២៩.០៧១ហិចតា ដែលមានការកើនឡើងចំនួន ១៣%កាលពីឆ្នាំ២០១១។ ប្រទេសអេស្បាញជាប្រទេសនាំមុខនៅអឺរ៉ុបដែលបានដាំពោត១១៦.៣០៧ហិចតា ដែលចំនួននេះមានការកើនឡើង២០%កាលពីឆ្នាំ២០១១។

ពីឆ្នាំ១៩៩៦ដល់២០១១ ដំណាំជីវបរិស្ថានបានចូលរួមចំណែកក្នុងនិរន្តភាពសន្តិសុខស្បៀង និងបំរែបំរួលអា កាសធាតុដោយបង្កើនតម្លៃនៃផលិតផលកសិកម្មចំនួន៩៨.២កោដដុល្លារអាមេរិក, ធ្វើអោយប្រសើឡើងនូវវិស័យបរិស្ថាន, ការទប់ស្កាត់សត្វល្អិតដោយបង្កើនផលិតផល៤៧៣លានគីឡូក្រាម, កាត់បន្ថយការបំភាយឧស្ម័នការ បូនិចចំនួន២៣.១កោដគីឡូក្រាមនៅឆ្នាំ២០១១, កាត់បន្ថយការប្រើប្រាស់រថយន្តតាមដងផ្លូវដែលមានចំនួនស្មើនឹង១០.២លាន, ការអភិរក្សឧស្ម័នជីវសាស្រ្តលើផ្ទៃដី១០៨.៧លានហិចតា, ការលប់បំបាត់ភាពក្រីក្រដោយ ជួយគ្រួសារកសិករតូចៗជាង១៥.០លាន ដែលក្នុងនោះមានសមាជិកសរុបជាង៥០លាននាក់ដែលជាអ្នកក្រជាងគេនៅលើពិភពលោក។ ដំណាំជីវបរិស្ថានជាដំណាំសំខាន់ វាក់ជាឱសថដែលនៅជាប់ជាមួយការអនុវត្តការដាំដុះ ដូចជាការដាំដំណាំឆ្លាស់ ការគ្រប់គ្រងភាពស៊ាំ ដូចនេះគឺត្រូវអនុវត្តការដាំដុះតាមបែបជីវបរិស្ថានតាមដែលអាចធ្វើទៅបាន។

កង្វះបច្ចេកទេសសមស្រប វិទ្យាសាស្រ្ត ថវិការ/និងពេលវេលាគ្រប់គ្រាន់ ព្រមទាំងប្រព័ន្ធគ្រប់គ្រង នឹងបន្តរជា បញ្ហាចម្បងសម្រាប់ការទទួលយក។ **<u>ការទទួលខុសត្រូវ ការសាកល្បង ដែលមិនមែនជាការបង្ខំ។</u>** គោលនយោបាយពិតជាត្រូវការចាំបាច់សម្រាប់គ្រួសារកសិករតូចតាច និងក្រីក្រនៅបណ្តាលប្រទេសក្នុងធ្វើការអភិវឌ្ឍន៍។

ដោយគ្រាន់តែតម្លៃនៃដំណាំជីវបរិស្ថានតែមួយមុខបានផ្តល់តម្លៃ១៥កោដដុល្លារអាមេរិកនៅឆ្នាំ២០១២។

<u>ក្តីសង្ឃឹមនាពេលអនាគត</u>៖ ការប្រុងប្រយ័ត្នប្រកបដោយសុទិដ្ឋិនិយម និងការទទួលបានជ័យជំនះជារៀងរាល់ឆ្នាំ ត្រូវបានគេទាយទុកដោយសារកំណើនខ្ពស់នៃការទទួលយកនូវគោលការណ៍ទាំងអស់នៃការដាំដុះក្នុងលក្ខណៈទីផ្សារដ៏ចាស់ទុំទាំងនៅប្រទេសអភិវឌ្ឍ និងប្រទេសកំពុងធ្វើការអភិវឌ្ឍន៍។

ISAAA គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមានការគាំទ្រដោយអង្គការសាធារណៈ និងឯកជន។ រាល់ការប៉ាន់ប្រមាណលើដំណាំជីវបរិស្ថានទាំងអស់ដែលបានផ្សាយនៅរាល់ការបោះពុម្ភផ្សាយទាំងអស់របស់ISAAA គឺជា ការប៉ាន់ស្មាន វាជាការវាយតម្លៃអំពីលក្ខណនានាដែលចូលរួមក្នុងការដាំដុះ។ សម្រាប់ព័តមានលម្អិតមាននៅក្នុង ISAAAលេខ៤៤ ស្ថានភាពទូទៅនៃការធ្វើវិនិយោគផ្នែកជីវបរិស្ថាន/ការគ្រប់គ្រងដំណាំដាំដុះ៖ ២០១២ ដែលសរសេរដោយ Clive James។ សម្រាប់ព័តមានបន្ថែមសូមមើលនៅក្នុងhttp://www.isaaa.org ឬទាក់ទងមជ្ឈមណ្ឌលISAAAអាស៊ីអាគ្នេយ៍តាមរយៈលេខ៖+63 49 536 7216 ឬអ៊ីម៉ែលinfo@isaaa.org